9. Clients must immediately inform company in the case clients know that the person who has no right to make Buy or Sell order used clients’ confidential information to make Buy or Sell order.

១០.អតិថិជនទទួលស្គាល់ និងយល់ព្រមថាការទិញ ឬលក់ឧបករណ៍និស្សន្ទតាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទគឺជាការទិញ ឬលក់រវាងអតិថិជនជាមួយក្រុមហ៊ុនសមភាគីកណ្តាល ដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យាដែលក្រុមហ៊ុនជាភ្នាក់ងារ។

10. Clients should recognize and agree that derivative Buy or Sell by derivative broker is the Buy or Sell between clients and Central Counter Party other side party of contract that company is the representative.

## ៤.ម៉ាជីន
## 4. Margin

១.អតិថិជនយល់ព្រមដាក់តម្កល់សាច់ប្រាក់ជាមួយក្រុមហ៊ុន ក្នុងគោលបំណងធ្វើការជួញដូរឧបករណ៍និស្សន្ទទៅតាមម៉ាជីនដែលកំណត់ដោយក្រុមហ៊ុនដែលអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន ក្នុងទំហំសាច់ប្រាក់មិនលើសពី ២០០,០០០,០០០ (ពីររយលាន) រៀល ឬ ៥០,០០០ (ហាសិបពាន់) ដុល្លាអាមេរិក។លើកលែងតែអតិថិជននោះជាវិនិយោគិនគុណវុឌ្ឍិដែលបំពេញលក្ខខណ្ឌតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

1.Clients agree to deposit cash with company in order to trade derivative based on the margin that is determined by company, complied with laws and regulations within the cash amount that is not over 200,000,000 (two hundred million)

riel or 50,000 (fifty thousand) US dollar. Except clients are qualification investor who meets conditions in accordance with law and regulation.

២.ក្រុមហ៊ុនត្រូវដាក់សាច់ប្រាក់អតិថិជន ក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទដាច់ដោយឡែកពីគណនីរបស់ក្រុមហ៊ុននៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក**។

2. The company should deposit the client's cash account separately from the company account at the securities settlement agent related to securities recognized by SECC.

៣.ក្រុមហ៊ុននឹងគណនាតម្លៃនៃឧបករណ៍និស្សន្ទនៅក្នុងគណនីរបស់អតិថិជន និងកែតម្រូវម៉ាជីនដែលបានដាក់តម្កល់ដោយអតិថិជននៅក្នុងក្រុមហ៊ុន យ៉ាងយូរត្រឹមចុងថ្ងៃជួញដូរដើម្បីឲ្យកម្រិតម៉ាជីននៅក្នុងគណនីរបស់អតិថិជនស្របតាមច្បាប់ បទប្បញ្ញត្តិ និងវិធានជាធរមាន។

3. Company will calculate the cost of derivative in client’s account and correct the margin which is deposited by clients in the company at the end of trading day to make the margin level of clients’ account paralleling with related measurement and provisions.

៤.អតិថិជនយល់ព្រមអនុវត្តម៉ាជីនរក្សាដែលកំណត់ដោយក្រុមហ៊ុនដែលអនុលោមតាមច្បាប់ បទប្បញ្ញត្តិនិងវិធានជាធរមាន។ ប្រសិនបើកម្រិតម៉ាជីនរបស់អតិថិជនទាបជាងម៉ាជីនរក្សា អតិថិជនត្រូវពិនិត្យពីភាពគ្រប់គ្រាន់នៃកម្រិតម៉ាជីនដូចដែលក្រុមហ៊ុនបានជូនដំណឹងទៅអតិថិជនតាមរយៈមធ្យោបាយដែលទទួលយល់ព្រមជាមុនពីអតិថិជនដូចជាលិខិតជាលាយលក្ខណ៍អក្សរ ទូរសារ ទូរសព្ទ អ៊ីម៉ែល ឬមធ្យោបាយអេឡិចត្រូនិចផ្សេងៗទៀតនិង អតិថិជនត្រូវដាក់សាច់ប្រាក់បំពេញបន្ថែមដើម្បីឲ្យកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនមិនទាបជាងម៉ាជីនដំបូង។ អតិថិជនត្រូវដាក់សាច់ប្រាក់បំពេញបន្ថែមម៉ាជីននៅក្នុងអំឡុងពេលជាក់លាក់ណាមួយដែលកំណត់ដោយក្រុមហ៊ុន។

4. Clients agree to take margin requirement determined by company and SECC. If client's margin level is lower than margin requirement client needs to check the sufficiency of margin level as the company used to inform electronic method and clients need to refill the cash to make margin level in client's account to be not lower than the initial margin. Clients should deposit the cash to refill the margin in the specific time determined by company.

៥.អតិថិជនអាចដកសាច់ប្រាក់ដែលបានដាក់តម្កល់ក្នុងករណីកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនខ្ពស់ជាងម៉ាជីនដំបូង។

5. Clients can withdraw the money in case that margin in clients’ account is higher than initial margin.

៦.ករណីក្រុមហ៊ុនមិនបានទទួលសាច់ប្រាក់បន្ថែមពីអតិថិជនក្នុងរយៈពេលដែលបានកំណត់ ក្រុមហ៊ុនមានសិទ្ធិដូចខាងក្រោម៖

6.If the company does not receive additional cash from clients within the determined time company has right as below:

ក.បដិសេធការដាក់បញ្ជាលក់ ឬទិញបន្ថែមរបស់អតិថិជន។

a. Rejecting clients’ additional Buy or Sell order

ខ.បិទរាល់ស្ថានភាពជួញដូរទាំងអស់ ឬមួយផ្នែករបស់អតិថិជន។

b. Closing all or a part of trading transaction of clients.

៧.ក្រុមហ៊ុនមិនត្រូវដកសាច់ប្រាក់របស់អតិថិជនឡើយ លើកលែងករណីដូចខាងក្រោម៖

7. Company should not withdraw clients’ cash except the cases as below.

ក.ក្រុមហ៊ុនធ្វើការទូទាត់ ឲ្យបុគ្គលណាមួយដែលមានសិទ្ធិ ក្នុងក្របខ័ណ្ឌនៃការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជន។

a. The Company makes payments to any person who is eligible within the framework of trading derivatives of clients.

ខ.ក្រុមហ៊ុនធ្វើការទូទាត់ថ្លៃសេវា កម្រៃជើងសា និងបន្ទុកចំណាយផ្សេងទៀតដែលអតិថិជនត្រូវបង់។

b. The company makes payment for the fees, commissions and other expenses that the client has to pay.

គ.ក្រុមហ៊ុនធ្វើការទូទាត់ឲ្យបុគ្គល ឬគណនីផ្សេងយោងតាមសំណើរជាលាយលក្ខណ៍អក្សររបស់អតិថិជន។

c. Company makes payments to individuals or another account according to the client's written request.

ឃ.ក្រុមហ៊ុនធ្វើការទូទាត់ ឬដកសាច់ប្រាក់ដែលតម្រូវដោយ **គ.ម.ក** ឬច្បាប់។

d. Company makes payment or withdraws the cash that is required by SECC or law.

## ៥.ការបិទការជួញដូរឧបករណ៍និស្សន្ទ
## 5.Derivative Trading Closing

១. ក្រុមហ៊ុនអាចចាត់វិធានការចំពោះអតិថិជន ប្រសិនបើមានស្ថានភាពណាមួយដូចខាងក្រោម៖
1. Company can take action to clients if there are any situations as mention below:

ក.អតិថិជនបានលាក់បាំង ឬផ្តល់ព័ត៌មានមិនពិត។
a. Clients hide and provide untruth information

ខ.អតិថិជនមិនអនុវត្តតាមប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ។
b. Client do not respect any items of this agreement

គ.ក្រុមហ៊ុនយល់ថា មានភាពចាំបាច់ក្នុងការបង្ការស្ថានភាពជួញដូរមិនប្រក្រតី ឬមានការអនុវត្តការជួញដូរឧបករណ៍និស្សន្ទមិនត្រឹមត្រូវ ឬល្មើសច្បាប់។
c. Company finds out that it is important to prevent unusual trading situation or having untrusted and anti-law derivative trading.

ឃ.ក្រុមហ៊ុនអនុវត្តតាមការតម្រូវរបស់ **គ.ម.ក** ។
d. Company follows the requirement of SECC.

២. វិធានការដែលក្រុមហ៊ុនអាចចាត់ចំពោះអតិថិជនដូចខាងក្រោម៖
2. The company policy may take action against client as below:

ក.បិទស្ថានភាពជួញដូរណាមួយ ឬបិទស្ថានភាពជួញដូរទាំងអស់របស់អតិថិជន ក្នុងគោលបំណងទូទាត់កាតព្វកិច្ចរបស់អតិថិជន។
a. Closing any or all trading transaction of clients in order to settle clients' obligation

ខ.កាត់បន្ថយ ឬដាក់កំហិតលើការជួញដូរឧបករណ៍និស្សន្ទរបស់អតិថិជន។
b. reducing or restricting on clients' derivatives trading.

## ៦.ផលប្រយោជន៍និងទំនាក់ទំនង
## 6. Benefit and Relationship

ក្រុមហ៊ុនត្រូវបញ្ជាក់រាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមាន ឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទក្នុងតារាង (២) ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិពាក់ព័ន្ធ។
Company must verify all benefit and relationship between company and other person who affect the company or derivative representative in table no. 2 which comply with condition and related agreement.

## ៧.ការតវ៉ា
## 7. Argument

១. ករណីក្រុមហ៊ុន ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ មិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើ បណ្តឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះ និងព័ត៌មានលម្អិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។
1. If company or derivative representative does not follow the content of this agreement. Client can fill the written complaint by having given name and detail information of person who handle this complaint of company.

២. ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយបណ្តឹងរបស់អតិថិជនក្នុងអំឡុងពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបណ្តឹង។
2. The company must agree to resolve client complaints within 7 days (Seven) of the working day after receiving the complaint.

## ៨.ការរក្សាការសម្ងាត់
## 8. Confidential

ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងក្របខ័ណ្ឌផ្តល់សេវាកម្មស្របតាមកិច្ចព្រមព្រៀងនេះ ទៅឲ្យបុគ្គលណាមួយឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម៖

Company agrees not to release clients' confidential information or other confidential information related to clients that company receives as service providing in this agreement to other person, except having any cases as mention below:

១. មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលព័ត៌មានសម្ងាត់នោះ។
1. Having written approval from clients by identifying the person who has right to obtain this confidential information

២.មានតម្រូវការពី **គ.ម.ក** ឬ តុលាការនៃព្រះរាជាណាចក្រកម្ពុជា។
2. Having requirement from SECC or Cambodian court

៣.មានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។
3. Having requirement from other related law and provision

## ៩.ការជូនដំណឹង
## 9. Notification

១.រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឲ្យអតិថិជនត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់និងបទប្បញ្ញត្តិលើកលែងតែមានសំណើជាលាយលក្ខអក្សរផ្សេងពីនេះពីអតិថិជន។
1. Every report and notification that provide to clients must follow this agreement or law and provision.

២.អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមដល់ក្រុមហ៊ុននៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាសយដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។
2. Clients agree to inform immediately to company when there is address changes or other contact information. If clients miss to notify company all of these changes, every report and notification will be to clients to the address that company know the last one.

## ១០.កិច្ចព្រមព្រៀងរួម
## 10. Agreement

រាល់បទបង្ហាញឬសេចក្តីថ្លែងការណ៍ឬកិច្ចព្រមព្រៀងផ្សេងទៀតមានខ្លឹមសារផ្ទុយពីកិច្ចព្រមព្រៀងនេះ ទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់រវាងភាគីទាំងសងខាងមិនមានអានុភាពអនុវត្តឡើយ។
On every presentation speech or other agreement that has contrast content from this agreement as written and verbal between these two parties is not effective

## ១១.ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង
## 11. Copy of Agreement

កិច្ចព្រមព្រៀងនេះធ្វើឡើងជាពីរច្បាប់ ដែលមានចុះហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឲ្យអតិថិជនមួយច្បាប់ភ្លាមៗ និងមួយច្បាប់ទៀតរក្សានៅក្រុមហ៊ុន។
This agreement is made by two copies which have signature and company's stamp or both parties' finger print. Company should give one copy to clients immediately and another copy is kept at company.

## ១២.ការកែប្រែ
## 12. Amendment

កិច្ចព្រមព្រៀងនេះ អាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើការវិសោធកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនត្រូវកែប្រែកិច្ចព្រមព្រៀងនេះឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលបានធ្វើវិសោធកម្មដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។
This agreement can be changed when there is agreement between both parties. When related provision and law that contrast from this agreement are amendment, Company must change this agreement to be the same as the amendment provision and law without any agreement from clients and should inform client in writing about changing this agreement.

## ១៣.ការចាត់តាំង
## 13. Assigning

អតិថិជនព្រមព្រៀងថា រាល់សិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវផ្ទេរទៅឲ្យប្រតិសិទ្ធិសាកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជន នៅក្នុងតារាងទី៣ ក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃទ្រព្យសម្បត្តិរបស់ អតិថិជនដែលមាននៅក្នុងក្រុមហ៊ុនដែលកើតឡើងដោយប្រតិបត្តិនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្ស័យធន អសមត្ថភាព ដីកាតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះក្រុមហ៊ុនត្រូវចាត់ចែងរាល់ការផ្ទេរទ្រព្យសម្បត្តិនោះ។

Client agrees that every right and obligation determined in this agreement will be transferred to Universal Successor Particular Successor and client's representative as in table no.3, in the event of a change in ownership of the Client's assets contained in Companies formed by law enforcement, client death, bankruptcy, disability, court warrant, or other reasons. In this case company should assign all property transfer.

## ១៤.ច្បាប់គ្រប់គ្រង
## 14. Management Law

១.កិច្ចព្រមព្រៀងនេះត្រូវស្ថិតនៅក្រោមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។
1. This agreement is officially under the law and provision of Cambodia.

២.រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះ អាចដោះស្រាយតាមនិតិវិធីដោះស្រាយវិវាទដែលកំណត់ដោយ **គ.ម.ក**។
2. Any dispute occurred from this agreement can be solved by dispute resolution procedure determined by SECC.

## ១៥.ការបញ្ចប់កិច្ចព្រមព្រៀង
## 15. Ending Agreement

១.ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃដល់ភាគីម្ខាងទៀត។
1. Each party can end this agreement anytime by prior notice in writing within 7 days to other party.

២.ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់សិទ្ធិ និងកាតព្វកិច្ចព្រមទាំងផលប្រយោជន៍ដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។
2. Both parties agree that ending this agreement is not affect the right and obligation as well benefit that has not completely finished for each party before ending this agreement.

## ១៦.កត្តាហានិភ័យ
## 16.Risk Factor

១.អតិថិជនបានសិក្សាពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ និងបានយល់ដឹងពីការជួញដូរឧបករណ៍និស្សន្ទ យន្តការ និងការអនុវត្តការជួញដូរ ការដាក់សាច់ប្រាក់តម្កល់ក្នុងគណនី កត្តាហានិភ័យនិងព្យសនកម្មដែលជាលទ្ធផល បណ្តាលមកពីការជួញដូរឧបករណ៍និស្សន្ទ។ អតិថិជនក៏បានយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ រួមទាំងសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភាគីនីមួយៗនៅក្នុងកិច្ចព្រមព្រៀងនេះ។
1. Clients have studied about risk related to derivative trading and understood about derivative trading, mechanism and trading implementation cash deposit in account risk factors that result from derivative trading. Clients also fully understand about related law and provision including right, obligation and responsibility of each party in this agreement.

២.អតិថិជនយល់ដឹង និងទទួលស្គាល់ថា ការជួញដូរឧបករណ៍និស្សន្ទ គឺជាការជួញដូរមួយប្រភេទដែលមានហានិភ័យខ្ពស់ ដោយថ្លៃមានការប្រែប្រួលលឿន។
2. Clients understand and recognize that derivative trading is a kind of trading that has high risk because of the Volatility.

៣.មុនចុះហត្ថលេខាជាមួយអតិថិជន ភ្នាក់ងារឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទាក់ទងដោយផ្ទាល់ជាមួយអតិថិជន បានពន្យល់ពីខ្លឹមសារនៃកិច្ចព្រមព្រៀងនេះដល់អតិថិជន និងបានពន្យល់លម្អិតអំពីវិធីសាស្ត្រនៃការដាក់បញ្ជាទាំងអស់ និងហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការដាក់បញ្ជានីមួយៗដល់អតិថិជន។ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទអាចផ្តល់ជូនអតិថិជននូវឯកសារផ្តល់ព័ត៌មានអំពីហានិភ័យ និងត្រូវពន្យល់លម្អិតអំពីហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ។
3. Before signing with client’s derivative representative who directly contact with clients has explained the content of agreement to clients and elaborated about the method of order and risks that might happen related to the method of each making order to clients.

<table>
<tr><td colspan="2">កិច្ចព្រមព្រៀងនេះមានសុពលភាពចាប់ពីពេលភាគីទាំងពីរបានព្រមព្រៀងគ្នា ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃខាងក្រោមៈ<br>This agreement is effective when the both parties have agreed by signature or finger print as below:</td></tr>
<tr><td>ហត្ថលេខា ឬស្នាមមេដៃ ឈ្មោះពេញ និងត្រា(ករណីស្ថាប័ន) របស់អតិថិជន<br>Signature or finger print / Full name and stamp (For organization) of client.</td><td>ហត្ថលេខា ឬស្នាមមេដៃ ឈ្មោះពេញ និងត្រា របស់ក្រុមហ៊ុន<br>Signature or finger print full name and stamp of company</td></tr>
<tr><td>កាលបរិច្ឆេទៈ ……….………………..…..<br>Date:</td><td>កាលបរិច្ឆេទៈ ……….………………..…..<br>Date:</td></tr>
</table>

| តារាងទី១<br>Table No.1 | | |
|---|---|---|
| *កម្រៃជើងសា ថ្លៃសេវា និង លាភការផ្សេងៗ*<br>Commission Service Fee and Incentive | | |
| *ប្រភេទកម្រៃ*<br>**(Fee Type)** | *ចំនួនប្រាក់*<br>**(Amount)** | *ការគណនា*<br>**(Calculation)** |
| កម្រៃជើងសា<br>(Commission) | | |
| ថ្លៃសេវា<br>(Service Fee) | | |
| លាភការផ្សេងៗ<br>(Incentive) | | |

| តារាងទី ២<br>Table No.2 | | |
|---|---|---|
| *ផលប្រយោជន៍ និង ទំនាក់ទំនង*<br>Benefit and Relationship | | |
| *ឈ្មោះ*<br>**Name** | *ទំនាក់ទំនងជាមួយក្រុមហ៊ុន*<br>**Relationship with company** | *ការពន្យល់ពីឥទ្ធិពល*<br>**Influence explanation** |
| | | |
| | | |
| | | |
| | | |
| | | |

## តារាងទី ៣
(Table No.3)

អ្នកតំណាងរបស់អតិថិជន
(Client Representative)

| ឈ្មោះអ្នកតំណាង<br>**Name of Representative** | អាសយដ្ឋាន និងលេខទំនាក់ទំនង<br>**Address & Contact** | ទំហំនៃការអនុញ្ញាតសិទ្ធិ<br>**Permission allowed** |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

# សេចក្តីប្រកាសទទួលស្គាល់ហានិភ័យ

## Announcement of Risk Acknowledgement

សេចក្តីប្រកាសទទួលស្គាល់ហានិភ័យនេះមិនបង្ហាញនូវហានិភ័យទាំងអស់ ដែលអាចកើតមានពីប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទនោះទេ ។ ការធ្វើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទអាចប្រឈមនឹងហានិភ័យខ្ពស់ និង មានភាពស្មុគស្មាញច្រើន ដូចនេះ អតិថិជនត្រូវពិចារណាលើប្រភេទឧបករណ៍និស្សន្ទ បទពិសោធន៍ និងប្រភពហិរញ្ញវត្ថុរបស់អតិថិជនផ្ទាល់ ដើម្បីប្រាកដថា អតិថិជនអាចធ្វើប្រតិបត្តិការ ជួញដូរឧបករណ៍និស្សន្ទបាន ។ ទោះបីជាអតិថិជនធ្លាប់មានបទពិសោធន៍ក្នុងការជួញដូរឧបករណ៍និស្សន្ទក៏ដោយ ក៏អតិថិជននៅតែត្រូវយល់ដឹងអំពីហានិភ័យចម្បងៗ ដូចខាងក្រោម ៖

This risk declaration does not represent all the risks arising from the trading derivatives. Derivatives trading tools is very risky and complicated, so Client need to consider the type of Derivatives, experience and financial resources of the client to ensure that the client can trade Derivatives. Even though the Client has experience in Derivatives trading, they still need to be aware of the following key risks:

### *១- ឥទ្ធិពលនៃឡេវើរ៉េច*
### 1.Effect of Leverage

មុននឹងអាចជួញដូរឧបករណ៍និស្សន្ទបាន ឈ្មួញជើងសាឧបករណ៍និស្សន្ទតម្រូវឲ្យ អតិថិជនដាក់សាច់ប្រាក់តម្កល់ ដែលត្រូវបានគេហៅថាម៉ាជីនដំបូង ។ ម៉ាជីនដំបូងនេះមាន ទំហំសាច់ប្រាក់តូចធៀបនឹងតម្លៃជាក់ស្តែងនៃឧបករណ៍និស្សន្ទ ប៉ុន្តែអនុញ្ញាតឲ្យអតិថិជន អាចធ្វើការជួញដូរ បានលើសពីទំហំសាច់ប្រាក់ជាក់ស្តែងដែលខ្លួនមាន តាមរយៈអនុភាព នៃឡេវើរ៉េច ។ ក្នុងអំឡុងពេលជួញដូរ បម្រែបម្រួលថ្លៃឧបករណ៍និស្សន្ទនឹងប៉ះពាល់សាច់ ប្រាក់តម្កល់របស់អតិថិជន ដែលអាចបង្កើតប្រាក់ចំណេញ ឬបង្កការខាតបង់ដល់អតិថិជន។ អតិថិជនអាចប្រឈមនឹងការខាតបង់ទាំងស្រុងនូវម៉ាជីនដំបូង និងសាច់ប្រាក់បន្ថែមដែលបានតម្កល់ជាមួយក្រុមហ៊ុន ដើម្បីរក្សាស្ថានភាពជួញដូររបស់ខ្លួន ។

Before trading derivatives, Derivative Broker requires client to deposit cash, which is called initial margin. The initial margin is small against the actual price of the derivatives trading, but allowed its client to trade beyond the actual amount of cash it had through leverage. During trading, price movements of the derivatives will affect the clients' deposits, which may generate profit or incur client losses. Client may be at risk of losing the entire initial margin and the additional cash invested with the company to maintain their trading transaction.

ក្នុងករណីកម្រិតម៉ាជីនរបស់អតិថិជនទាបជាងម៉ាជីនរក្សា អតិថិជននឹងទទួលបាន ម៉ាជីនខលពីឈ្មួញជើងសាឧបករណ៍និស្សន្ទ ដែលតម្រូវឲ្យអតិថិជនត្រូវដាក់ប្រាក់បំពេញ បន្ថែមទៅក្នុងគណនី ក្នុងរយៈពេលជាក់លាក់មួយ ដើម្បីឲ្យកម្រិតម៉ាជីនក្នុងគណនីរបស់ អតិថិជនកើនឡើងដល់លក្ខខណ្ឌតម្រូវ។ ក្នុងករណីអតិថិជនមិនបានដាក់សាច់ប្រាក់បំពេញបន្ថែមទៅលើគណនីតាមការកំណត់ អតិថិជនមិនអាចដាក់បញ្ជាទិញ-លក់ឧបករណ៍និស្សន្ទបន្ថែម ហើយរាល់ស្ថានភាពជួញដូរឧបករណ៍និស្សន្ទទាំងអស់ ឬ មួយផ្នែករបស់ អតិថិជនត្រូវបានបិទ ដែលអាចបង្កការខាតបង់ដល់អតិថិជន ។

In case the client margin level is lower than the limit margin, client will receive a margin call from derivatives broker, which is required client to top up the account within a certain period of time in order for the margin level in client's account to reach the required margin. In case client does not deposit the top-up cash on the account as specified, Client cannot place an order to Buy or Sell derivatives anymore and all derivatives trading transaction of the client are closed, which can cause losses to the client.

### ២- ហានិភ័យនៃបញ្ជាបញ្ឈប់ការខាត
### 2.Risks of Stop-Loss Order

នៅក្នុងកាលៈទេសៈខ្លះ ដូចជាបម្រែបម្រួលថ្លៃលឿន ឬការបិទទីផ្សារ បញ្ជាបញ្ឈប់ ការខាតមិនមានប្រសិទ្ធភាពនោះទេពេលគឺ បញ្ជាបញ្ឈប់ការខាតមិនអាចការពារអតិថិជនពីការខាតបានគ្រប់ពេលនោះទេ ។

In some circumstances, such as a quick price hike or a market closure, a stop loss order which cannot protect the client every time from the loss.

ក្នុងករណីមានភាពមិនប្រក្រតីនៃប្រព័ន្ធអេឡិចត្រូនិក បញ្ជារបស់អតិថិជនមិនអាចត្រូវបានអនុវត្ត ដែលអាចធ្វើឲ្យអតិថិជនប្រឈមនឹងហានិភ័យនៃការខាតបង់ក្នុងការដាក់បញ្ជាជួញដូរឧបករណ៍និស្សន្ទ ទោះបីជាអតិថិជនបានកម្រិតទំហំខាតជាក់លាក់រួចហើយក៏ដោយ ។

In the event of a malfunction of the electronic system, the client's order may not be enforced, which may place client at risk of losing derivatives trading order, even if client has a certain size limit.

### ៣- បម្រែបម្រួលទីផ្សារមូលដ្ឋាន
### 3.Underlying Market Volatility

ឧបករណ៍និស្សន្ទគឺជាឧបករណ៍ដែលអនុញ្ញាតឲ្យអតិថិជនជួញដូរលើបម្រែបម្រួល ថ្លៃក្នុងទីផ្សារមូលដ្ឋាន ឬ ឧបករណ៍មូលដ្ឋាន ។ ទោះបីជាថ្លៃឧបករណ៍និស្សន្ទត្រូវបានផ្តល់ ដោយក្រុមហ៊ុនសមភាគីកណ្តាលក៏ដោយ ក៏ថ្លៃនោះកើតចេញពីទីផ្សារមូលដ្ឋាន ឬ ឧបករណ៍មូលដ្ឋាន ។ ដូចនេះ អតិថិជនត្រូវយល់ថា បម្រែបម្រួលទីផ្សារមូលដ្ឋានអាច ជះ ឥទ្ធិពលលើថ្លៃឧបករណ៍និស្សន្ទ និង ប្រាក់ចំណេញរបស់អតិថិជន ។

Derivatives is a tool that allows a Client to trade on Volatility of underlying market or underlying products. Although the Derivatives is provided by Central Counter Party, it comes from the underlying market or underlying products. Therefore, clients need to understand that changes in the underlying market can affect the cost of the Derivatives and the profitability for the Client.

អតិថិជនគួរយល់ដឹងផងដែរអំពីគម្លាតនៃព្រឹត្តិការណ៍ដែលអាចបង្កើតប្រាក់ចំណេញ ឬបណ្តាលឲ្យខាតនៅក្នុងគណនីអតិថិជន។គម្លាតនៃព្រឹត្តិការណ៍អាចកើតឡើងនៅពេលទីផ្សារមូលដ្ឋានបើក ឬបិទ។ អតិថិជនត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីតាមដានការវិនិយោគរបស់ខ្លួនឲ្យបានទៀងទាត់។

Clients should also be aware of transaction gaps that could generate profit or cause losses in client’s accounts. Transaction gaps can occur when the underlying market is open or close. Clients need to have enough time to monitor their investments regularly.

### ៤- ការផ្អាក ឬការដាក់កំហិតនៃការជួញដូរ
### 4.Suspension or Restriction of Trading

លក្ខខណ្ឌអសន្ទនីយភាពនៃទីផ្សារ ឬ ការអនុវត្តនៃវិធាននៃទីផ្សារមួយចំនួន អាចបង្កើតហានិភ័យនៃការខាតដោយសារអាចមានការលំបាក ឬ មិនអាចធ្វើប្រតិបត្តិការទូទាត់ ឬ ការកាត់កងស្ថានភាពជួញដូរបាន ។

Market fluctuations or the enforcement of certain market rules may create the risk of loss due to the difficulty or inability to execute clearing or settlement positions.

### *៥- សាច់ប្រាក់តម្កល់*
### 5.Deposited Cash

អតិថិជនត្រូវប្រាកដថា សាច់ប្រាក់ដែលខ្លួនបានដាក់តម្កល់សម្រាប់ ប្រតិបត្តិការ ជួញដូរឧបករណ៍និស្សន្ទ តាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវបានរក្សាទុកនៅ ក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹង មូលបត្រដែលទទួលបាន ការទទួលស្គាល់ពី *គ.ម.ក* ។ អតិថិជនត្រូវយល់ដឹងថា ការដាក់ តម្កល់សាច់ប្រាក់ប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទនៅកន្លែងផ្សេង ជាអំពើផ្ទុយពីបទប្បញ្ញត្តិ និងប្រឈមនូវហានិភ័យខ្ពស់ ។

Client must make sure that the cash they have deposited for trading through a derivative broker is kept in the client's cash account, at the relevant cash settlement and securities recognized by the SECC. Clients need to be aware that depositing cash elsewhere is against the law and is a very high risk.

### *៦- កម្រៃជើងសា ថ្លៃសេវា និងចំណាយផ្សេងៗ*
### 6.Commission, Fees and other Charges

មុនធ្វើការជួញដូរ អតិថិជនត្រូវទទួលបានការពន្យល់ច្បាស់លាស់អំពីកម្រៃជើងសារ ថ្លៃសេវា ការប្រាក់ឆ្លងថ្ងៃ(Swap) និងចំណាយផ្សេងៗ ដែលអតិថិជនត្រូវទទួលបន្ទុក ។ ចំណាយទាំងនេះនឹងប៉ះពាល់ដល់ប្រាក់ចំណេញសុទ្ធ ឬ កំណើននៃការខាតរបស់អតិថិជន ។

Before trading, client must obtain a clear explanation of commissions, fees, swaps and other costs incurred by broker. These costs will affect net profit or lost for clients.

### *៧- ហានិភ័យរូបិយប័ណ្ណ*
### 7.Currency Risks

ប្រតិបត្តិការជួញដូរជារូបិយប័ណ្ណបរទេសនឹងប៉ះពាល់ដល់ការចំណេញ ឬ ខាតរបស់អតិថិជន ដោយសារបម្រែបម្រួលនៃអត្រាប្តូរប្រាក់ដែលតម្រូវឲ្យប្តូរពី រូបិយប័ណ្ណ បរទេសនោះទៅជារូបិយប័ណ្ណផ្សេងទៀត ។

Foreign exchange transactions will affect client profit or loss as a result of the change in the exchange rate required to convert from one foreign currency to another.

### *៨- ហានិភ័យសន្ទនីយភាព*
### 8.Liquidity Risks

ឧបករណ៍និស្សន្ទខ្លះអាចមានកម្រិតសន្ទនីយភាពទាប ឬ មិនមានសន្ទនីយភាព ដោយសារការថយចុះនៃតម្រូវការ ដែលធ្វើឲ្យអតិថិជនមិនអាចលក់ឧបករណ៍និស្សន្ទនោះ ឬ មិនអាចទទួលបានព័ត៌មានអំពីថ្លៃឧបករណ៍និស្សន្ទនោះ ឬ ហានិភ័យពាក់ព័ន្ធដោយងាយស្រួល ។

Some Derivative may have a low index or no index due to a decrease in demand that prevents the clients from selling derivatives or an inability to obtain information about the cost of the derivative or related risks easily.

## *៩- ហានិភ័យនៃការអនុវត្តបញ្ជា*
## 9.Execution Risks

ហានិភ័យនេះអាចកើតឡើងក្នុងករណីដែលបញ្ជាទិញ-លក់ឧបករណ៍និស្សន្ទ មិនត្រូវបានអនុវត្តភ្លាមៗ។ ឧទាហរណ៍ ៖ អាចមានការពន្យាពេល រវាងពេលដែលអតិថិជនដាក់ បញ្ជានិង ពេលដែលបញ្ជាត្រូវបានអនុវត្ត ។ ដូចនេះ បញ្ជាអាចមិនត្រូវបានអនុវត្តនៅក្នុងថ្លៃ ដែលអតិថិជនរំពឹងទុក ។

The risk can occur if Buy or Sell derivatives order is not implemented immediately. For example, there may be a delay when the client places the order and when the order is executed. As such, the order may not be implemented at the client's expected price.

ហានិភ័យនេះក៏អាចកើតមានក្នុងករណីជួញដូរក្រោយទីផ្សារបិទផងដែរ ។ អតិថិជនត្រូវដឹងថា ថ្លៃសម្រាប់ការជួញដូរអាចមានភាពខុសគ្នាពីថ្លៃបិទ នៃឧបករណ៍មូលដ្ឋានពោល គឺគម្លាតថ្លៃនៅពេលទីផ្សារបិទ អាចមានទំហំធំជាងគម្លាតថ្លៃនៅពេលទីផ្សារបើក ។

This risk can also occur in the case of after-market trading. Clients need to be aware that trading prices can be different from the closing price of underlying products, that is, the price gap at the closing market can be larger than the price gap when the market is open.

## *១០- ហានិភ័យសមភាគី*
## 10.Counterparty Risks

អតិថិជនត្រូវដឹងថា ការជួញដូរឧបករណ៍និស្សន្ទតាមរយៈឈ្មួញជើងសាឧបករណ៍ និស្សន្ទ គឺជាការជួញដូររវាងអតិថិជន និងក្រុមហ៊ុនសម ភាគីកណ្តាលដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យា ដែលឈ្មួញជើងសាឧបករណ៍និស្សន្ទជាភ្នាក់ងារ។ ការណ៍នេះ បញ្ជាក់ថា ក្រុមហ៊ុនសមភាគី កណ្តាល គឺជាសមភាគីរបស់អតិថិជននៅក្នុងប្រតិបត្តិការជួញដូរ ឧបករណ៍និស្សន្ទ ។ ដូចនេះ មុនពេលធ្វើប្រតិបត្តិការជួញដូរ អតិថិជនត្រូវស្វែងយល់អំពី អាជ្ញាបណ្ណ វិធានប្រតិបត្តិការឧបករណ៍និស្សន្ទ និង ព័ត៌មានសំខាន់ផ្សេងទៀតរបស់ក្រុមហ៊ុនសមភាគីកណ្តាល ដែលឈ្មួញជើងសាឧបករណ៍និស្សន្ទ បានតភ្ជាប់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទជាមួយ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលអាចសម្រួលដល់អតិថិជនក្នុងការ ធ្វើប្រតិបត្តិការជួញដូរ និងកាត់បន្ថយនូវហានិភ័យដែលអាចកើតមាន ។

Clients need to know that trading derivatives through Derivatives Broker is a trade between the client and his or her Central Counter Party, which is the other side of the contract to which the Derivative Broker is an agent. This implies that the Central Counter Party is the client's counterpart in the trading of derivatives. Therefore, before trading a client must find out about the license, the operating instrument, the index and other key information of the Central Counter Party, where the Derivatives Broker is connected to the trading instrument with relevant provisions that may facilitate the client in Trading transactions and mitigating potential risks.

## *១១- ការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិច*
## 11.Electronic Trading

សម្រាប់ការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិក អតិថិជនអាចប្រឈមនឹងហានិភ័យ ទាក់ទងនឹងប្រព័ន្ធជួញដូរដែលអាចមានការខូចផ្នែករឹង ( Hardware ) និង/ឬផ្នែកទន់ ( Software ) ។ ការខូចផ្នែកណាមួយនៃប្រព័ន្ធជួញដូរ បញ្ជាទិញ-លក់ របស់អតិថិជនអាច មិនត្រូវបានអនុវត្តតាមការដាក់បញ្ជា ឬ មិនត្រូវបានអនុវត្តទាំងស្រុង ។ ក្នុងករណីនេះ អតិថិជន ត្រូវបញ្ជាក់ជាមួយក្រុមហ៊ុនដើម្បីធ្វើការដោះស្រាយ ។

For Electronic trading, clients may be exposed to risks associated with trading systems that may have hardware or software failures. Damage to any part of the Client Buy or Sell order may not be complied with or may not be fully implemented. In this case, the client must confirm with the company for settlement.

ខ្ញុំសូមប្រកាសទទួលស្គាល់ថា បានទទួលការពន្យល់ពីភ្នាក់ងារជើងសាឧបករណ៍ និស្សន្ទ និងយល់ដឹងអំពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ ។

I acknowledged that I have received explanations from Derivatives Representative and are aware of the risks involved in the derivatives trading.

| សម្រាប់អតិថិជនជារូបវន្តបុគ្គល<br>For Individual Client | សម្រាប់អតិថិជនជានីតិបុគ្គល<br>For Institutional Client |
|---|---|
| ហត្ថលេខា ឈ្មោះរបស់អតិថិជន និងកាលបរិច្ឆេទ<br>Signature, Name of client and date | ហត្ថលេខា ឈ្មោះរបស់អ្នកតំណាងក្រុមហ៊ុន<br>ឈ្មោះរបស់ក្រុមហ៊ុន ត្រា និងកាលបរិច្ឆេទ<br>Signature, Name of Company Representative<br>Name of Company, Company's Stamp and Date |
| កាលបរិច្ឆេទ៖ ………..……………...……..<br>Date: | កាលបរិច្ឆេទ៖ ………..……………...……..<br>Date: |